# ម៉ាកស៍វ្យូ ថេកស្ទាយ (ខេមបូឌា) ខូអិលធីឌី

MAX VIEW TEXTILES (CAMBODIA) CO., LTD

## កិច្ចព្រមព្រៀង

ដោយសារតែក្រុមហ៊ុនខ្វះវត្ថុធាតុដើម ហើយការបញ្ជាទិញក្រណាត់មិនទាន់មកដល់ទាន់ពេលវេលាមានការយឺតយ៉ាវ ធ្វើអោយក្រុមហ៊ុនប្រឈមមុខនិងការខ្វះខាតទំនិញធ្វើក្នុងរយៈពេលខ្លីនេះ ហើយធ្វើអោយផ្នែកខ្លះៗគ្មានទំនិញធ្វើគ្រប់គ្រាន់។ អាស្រ័យដូចនេះហើយថ្នាក់ដឹកនាំក្រុមហ៊ុនក៏បានអញ្ជើញតំណាងសហជីព តំណាងកម្មករ ស៊ុប មកពិគ្រោះពិភាក្សាគ្នា ហើយបានសំរេចដូចខាងក្រោមៈ

- បច្ចុប្បន្នក្រុមហ៊ុនខ្វះវត្ថុធាតុដើម ដែលបណ្ដាលអោយច្រវ៉ាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិកចំនួន ២២០ នាក់ (ស្រី ១៥៤ នាក់ ) ក្នុងចំណោមកម្មករនិយោជិកសរុប ចំនួន ២២០ នាក់ (ស្រី ១៥៤ នាក់ ) (ក្នុងប្រព័ន្ធព្យួរកិច្ចសន្យាការងារ កម្មករនិយោជិកមានចំនួន៤០៧នាក់ (ស្រី ២៧៥នាក់) ហើយក្នុងចំណោមកម្មករនិយោជិក ៤០៧ នាក់កម្មករដែលបានលាឈប់ពីក្រុមហ៊ុនចំនួន ១៨៧នាក់ (ស្រី ១២១នាក់) រយៈពេល ៥៨ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០២៣ រហូតដល់ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០២៣។
- អំឡុងការឈប់សំរាកនៃកម្មករនិយោជិកទាំងអស់ត្រូវគិត ៥០% នៃប្រាក់ខែគោល និងអត្ថប្រយោជន៍ផ្សេងៗត្រូវគិត ៥០% ទាំងអស់ លើកលែងតែៈ
    - លុយឡានប្រាក់ជួលនៃការស្នាក់នៅរក្សាទុកនៅដដែល
    - លុយព្រីម គិតសមាមាត្រតាមថ្ងៃដែលមកធ្វើការ។
- កម្មករនិយោជិកទាំងអស់ត្រូវត្រលប់មកធ្វើការវិញតាមកាលបរិច្ឆេទដែលបានកំណត់។
- អំឡុងនៃការឈប់សំរាកនេះ ក្នុងអំឡុងចន្លោះពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០២៣ ដល់ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០២៣។
- ក្រុមហ៊ុននឹងបើកផ្ដល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិត (៥០% នៃប្រាក់ខែគោល) នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០២៣។

សេចក្ដីសំរេចខាងលើនេះ សូមជ្រាបជាព័ត៌មាន។

បានឃើញ និងឯកភាពពី

| តំណាងសហជីព និងតំណាងកម្មករ | ផ្នែករដ្ឋបាល | នាយកក្រុមហ៊ុន |
|---|---|---|
| សន ចិន្តា ខឹម តុលា កុយ ស្រីល័ក្ខណ៍ គូ ដាវ៉េត | | ម៉ាកស៍ វ្យូ ថេកស្ទាយ (ខេមបូឌា) MAX VIEW TEXTILES (CAMBODIA) Co., Ltd. KINGDOM OF CAMBODIA |